ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៥០៨
ចុះថ្ងៃទី២៩.០៤.២០១៩

សាលដីកា
លេខ: ៥៤ "ក្រVI.គ.ធ"
ចុះថ្ងៃទី២០-១០-២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជា សាធារណៈ នៅសាលាឧទ្ធរណ៍ភ្នំពេញនាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ដោយមាន ៖

**សមាសភាពក្រុមប្រឹក្សា**

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធាន |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |

**តំណាងមហាអយ្យការ**

| | | |
|---|---|---|
| លោកស្រី | [redacted] | ជាព្រះរាជអាជ្ញា |

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ: ៥០៨ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ដែលមាន ៖

១-ជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] វ៉ូរ៉ាផា) ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរធ្វើចំការ ទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណងយួន ខេត្តលុបបូរី ទីលំនៅបច្ចុប្បន្នស្នាក់ [redacted] ស្រុកណងមួង ខេត្តលុបបូរី ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) មានប្តីឈ្មោះ [redacted] មានកូនចំនួន០៣នាក់ ជានីតិជន ទោសពីមុនគ្មាន។

**ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ: ៤៥២៦ "ជ១" ង.ឃ.ង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។**

២-ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT ([redacted] រ៉ូថៃរ៉ាត់) ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ សាសនាព្រះពុទ្ធ មុខរបរកម្មករ ទីកន្លែងកំណើតនៅឃុំយ៉ាងថូន ស្រុកណងយួន ខេត្តលុបបូរី ទីលំនៅបច្ចុប្បន្នស្នាក់នៅ [redacted] ខេត្តប្រាធុមថានី ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (ស) មានប្តីឈ្មោះ [redacted] មានកូនចំនួន០១នាក់ ជានីតិជន ទោសពីមុនគ្មាន។

**ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៤៥២០ "ជ១" ង.ឃ.ង ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។**



Scanned with CamScanner

ជាប់ចោទពីបទ៖ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** (ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូប្រទេសជប៉ុន) ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃ ០៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ដោយមានលោក [redacted] **ហ្វូឡាយ** ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរ។

ដោយមានលោកស្រី [redacted] **បញ្ចរ៉ា** ជាអ្នកបកប្រែភាសាថៃ។

## **ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ វេលាម៉ោង២៣ និង៥០នាទី មន្ត្រីនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន និងដោយសហការជាមួយសមត្ថកិច្ចគយ និងរដ្ឋាករ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ បានធ្វើការឃាត់ខ្លួនជនត្រូវចោទជាអ្នកដំណើរចំនួន០២នាក់ មានឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA៨៥៧៨៨៩ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ និងឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ AA៨៧៣៨៩០៨ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៧ នៅចំណុចស្ថានីយ៍អ្នកចេញដំណើរ ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូ ប្រទេសជប៉ុន តាមជើងហោះហើរលេខ NH៨១៨ និងបានឆែកឆេរក្នុងអាវរងាររបស់ជនត្រូវចោទទាំង០២នាក់ រកឃើញមានម្សៅក្រាមពណ៌ស ប្រភេទមេតំហ្វេតាមីនដែលលាក់បង្កប់ក្នុងអាវរងាររបស់ជនត្រូវចោទឈ្មោះ [redacted] RUTHAIRAT មានទម្ងន់សរុប ២ ៧៥៦,៤៤ ក្រាម និងរបស់ជនត្រូវចោទឈ្មោះ [redacted] WORAPHA មានទម្ងន់សរុប ១ ៧៥០,៧៦ ក្រាម។ ចំណែកឈ្មោះ ក្វាង ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ជនជាតិថៃ ប្រើប្រាស់ទូរស័ព្ទលេខ [redacted] និងលេខ [redacted] ៣៥៣ ដែលជាម្ចាស់គ្រឿងញៀន និងជាមេក្លោង ជាអ្នករៀបចំចាត់ចែង និងប្រគល់សារធាតុញៀនឱ្យជនត្រូវចោទទាំង០២នាក់ នេះនៅខេត្តសៀមរាបនោះ បានគេចខ្លួនបាត់។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តីលេខៈ **១០៧ ក១.ក្រ១១ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. រឹបអូស និងបំផ្លាញចោលនូវវត្ថុតាងសារធាតុញៀនដូចមានក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ ១៦៥៨ វ.វ.ត ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ រួមមាន៖

ក.សំណាកគ្រឿងញៀនសល់ពីការដកហូតធ្វើកោសល្យវិច័យ នៃម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ២,៧៥៦.៤៤ (ពីរពាន់ប្រាំពីររយហាសិបប្រាំមួយក្រាម និងសែសិបបួន)ក្រាម របស់ឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ។

ខ.សំណាកគ្រឿងញៀនសល់ពីការដកហូតធ្វើកោសល្យវិច័យ នៃម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ១,៧៥០.៧៦ (មួយពាន់ប្រាំពីររយហាសិបក្រាម និងចិតសិបប្រាំមួយ) ក្រាម របស់ឈ្មោះ [redacted] RUTHARAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ។



Scanned with CamScanner

ដែលរក្សាទុកនៅឃ្លាំងតម្កល់វត្ថុចាប់យករបស់សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ តាមមាត្រា ៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ប្រគល់វត្ថុតាងជាសារធាតុញៀន ដែលបានសម្រេច ក្នុងចំណុចទី១ នៃសេចក្តីសម្រេចខាងលើ ជូនគណៈកម្មការបំផ្លាញគ្រឿងញៀន នៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨។

**-បានឃើញ** សាលក្រមព្រហ្មទណ្ឌលេខៈ **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១. ផ្តន្ទាទោសជនជាប់ចោទ

១.១ ឈ្មោះ [redacted] WORAPHA ភេទស្រី អាយុ៤២ឆ្នាំ ជនជាតិថៃ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦០លានរៀល (ហុកសិបលានរៀល)។

១.២ ឈ្មោះ [redacted] RUTHAIRAT ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិថៃ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៦០លានរៀល (ហុកសិបលានរៀល)។

១.៣ ឈ្មោះ [redacted] KANOKNUD ហៅ ហ្វាង ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិថៃ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣០ឆ្នាំ (សាមសិបឆ្នាំ) និងពិន័យជាប្រាក់ចំនួន ៨០លានរៀល (ប៉ែតសិបលានរៀល)។

**ពីបទៈ រក្សាទុក, ដឹកជញ្ជូន, ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. ចេញដីកាបង្គាប់ឲ្យចាប់ខ្លួនឈ្មោះ [redacted] KANOKNUD **ហៅ ហ្វាង** ភេទស្រី អាយុ៣៦ឆ្នាំ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.វត្ថុចាប់យកមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យក ពីអយ្យការអមសាលាដំបូងរាជធានីភ្នំពេញលេខ ៧៧០ប.រ.ត ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ មាន ៖ ១. ម្សៅក្រាមពណ៌សថ្លា ទម្ងន់សរុប ២,៧៥៦.៤៤ (ពីរពាន់ប្រាំពីររយហាសិបក្រាម និងសែសិបបួន), និង ២. ក្រាមពណ៌សថ្លា ទម្ងន់សរុប ១,៧៥០.៧៦ (មួយពាន់ប្រាំពីររយហាសិបក្រាម និងចិតសិបប្រាំមួយ) សម្រេចរឹបអូសតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៨៣ និងមាត្រា៨៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន , ៣. ទូរស័ព្ទម៉ាក Oppo ពណ៌ស-ផ្កាឈូក មិនដំណើរការ ០១គ្រឿង និងម៉ាកHUAWEI ពណ៌ទឹកមាស មិនដំណើរការ ០១គ្រឿង និងអត្តសញ្ញាណប័ណ្ណជនជាតិថៃ ចំនួន០១សន្លឹក, លិខិតឆ្លងដែនចំនួន០២ក្បាល និងសំបុត្រយន្តហោះចំនួន០១សន្លឹក សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] WORAPHA, និងឈ្មោះ [redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ ហ្វាង និងប្រកាសជាសាធារណៈ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩ ចំពោះ



Scanned with CamScanner

មុខជនជាប់ចោទឈ្មោះ [redacted] WORAPHA, និងឈ្មោះ [redacted] RUTHAIRAT និងកំបាំងមុខជនត្រូវចោទឈ្មោះ [redacted] KANOKNUD ហៅ ក្វាង។

ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**-បានឃើញ** សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខៈ **១៧៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩** របស់លោក **ឈាវ ហ្វឡាយ** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] **វ៉ូរ៉ាផា**) និងឈ្មោះ [redacted] RUTHAIRAT [redacted] **រ៉ូថៃរ៉ាត់**) សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុច **នៃសេចក្តីសម្រេចទាំងមូល**។

**-បានឃើញ** របាយការណ៍រឿង ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ភ្នំពេញ។

## <u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ [redacted] WORAPHA [redacted] **វ៉ូរ៉ាផា**) (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT ([redacted] **រ៉ូថៃរ៉ាត់**) (វត្តមាន)

-លោក [redacted] **ហ្វឡាយ** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងពីរ (វត្តមាន)

-លោកស្រី [redacted] **បញ្ញារ៉ា** ជាអ្នកបកប្រែភាសាថៃ (វត្តមាន)

-ប្រធានក្រុមប្រឹក្សា **អានរបាយការណ៍សង្ខេបរឿង**

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] **វ៉ូរ៉ាផា**) បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍នេះ ព្រោះនៅខាងប្រទេសថៃបានចាប់បានឈ្មោះ **ក្វាង** ហើយ ហើយខ្លួនចង់ទៅប្រទេសថៃវិញ។ ខ្លួនមិនបានដឹងថាអាវរងារនោះមានលាក់បង្កប់ថ្នាំញៀននោះទេ ពីព្រោះឈ្មោះ **ក្វាង** បានប្រាប់ថាក្នុងអាវរងារនោះមានលាក់បង្កប់ថ្នាំកម្លាំង គឺសម្រាប់ជំនួយផ្លូវភេទ។ ខ្លួនបានទៅជួបឈ្មោះ **ក្វាង** និងបុរសម្នាក់ទៀតជាជនបរទេស នៅខេត្តសៀមរាប។ ពេលនោះឈ្មោះ **ក្វាង** បានយកអាវរងារចំនួន០៣ ដែលមានពណ៌ខ្មៅចំនួន០២ និងពណ៌ប្រផេះចំនួន០១ ហើយមានថ្នាំសម្រើប ដែលលាក់ទុកបង្កប់នៅខាងក្នុង។ ក្រោយមក ខ្លួនក៏បានយកអាវទាំងបីខាងលើមកសណ្ឋាគារដើម្បីរៀបចំដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ខ្លួនចំនួន០១ និងបានដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ប្អូនថ្លៃខ្លួនចំនួន០២។ លុះដល់វេលាម៉ោងដប់បួន ពួកខ្លួនក៏បានចាកចេញពីសណ្ឋាគារ ឡើងជិះរថយន្តតាក់ស៊ីដែលឈ្មោះ **ក្វាង** ជាអ្នករៀបចំ ធ្វើដំណើរឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបានមកដល់ព្រលានយន្តហោះ នៅវេលាម៉ោងដប់ប្រាំបួន រួចក៏បានត្រួតពិនិត្យចូល (CHECK IN) ហើយក៏បន្តទៅត្រួតពិនិត្យវ៉ាលីស និងកាបូបយួរដៃខាងលើបន្ថែមទៀត។ ដោយសមត្ថកិច្ចមានការសង្ស័យទៅលើកាបូបយួរដៃរបស់ខ្លួន និងប្អូនស្រីថានៅក្នុងអាវរងារ ក៏បានធ្វើការហែកត្រួតពិនិត្យបានរកឃើញ ក្រាមពណ៌ស ជាច្រើនផងលាក់បង្កប់ក្នុងអាវទាំងបី បន្ទាប់មកសមត្ថកិច្ចក៏បានយកក្រាមនោះមកធ្វើតេស្តទៅចំពោះមុខខ្លួន បង្ហាញថាវាជាគ្រឿងញៀន ប្រភេទមេតំហ្វេ

តាមីន (ICE) រួចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនស្គាល់ឈ្មោះ **ភ្វាង** ប្រហែលជា ១០ ជាង ហើយ។ ឈ្មោះ **ភ្វាង** បានរៀបចំឲ្យខ្លួនទៅប្រទេសជប៉ុនបានម្តង ដោយឈ្មោះ **ភ្វាង** ជាអ្នកចំណាយទាំងអស់។ ក្នុងការយកថ្នាំសម្រើបនេះទៅប្រទេសជប៉ុន ឈ្មោះ **ភ្វាង** សន្យាថា ឲ្យលុយពួកខ្លួនម្នាក់ៗ ៥០.០០០ បាត នៅពេលដែលត្រឡប់មកពីប្រទេសជប៉ុនវិញ។ ខ្លួនមិនទាន់ទទួលបានលុយនោះទេ។ អាវរងានោះ ក្រាស់ ខ្លួនមិនអាចមើលឃើញថ្នាំញៀននៅក្នុងអាវទេ តែខ្លួនដឹងថាវាជាថ្នាំសម្រើប។ ខ្លួនទទួលស្គាល់ថា ថ្នាំនោះខ្លួនជាអ្នកយកទៅ តែខ្លួនមិនបានដឹងថា ជាថ្នាំញៀននោះទេ។ ខ្លួនគឺកសិករ ដែលមានចំណូលក្នុងមួយឆ្នាំ ប្រហែល ១០០.០០០ បាត។ ខ្លួនទទួលស្គាល់ចម្លើយ ដែលបានឆ្លើយទៅសាលាដំបូង។ សំណូមពរឲ្យតុលាការលើកលែងទោសប្រកាន់លើរូបខ្លួនផង។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT [redacted]រ៉ូថៃរ៉ាត់) បានឆ្លើយនាពេលសវនាការថា៖ ខ្លួនត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] WORAPHA [redacted]វ៉ូរ៉ាផា)។ ខ្លួនបានទៅប្រទេសជប៉ុនបាន ១ដង ហើយលើកនេះ ជាលើកទី២។ ខ្លួនទទួលស្គាល់អង្គហេតុដែលបងថ្លៃខ្លួនបាននិយាយ។ ខ្លួនមានអាវរងានោះ ២ ព្រោះមួយទុកឲ្យកូនខ្លួនពាក់។ ឈ្មោះ **ភ្វាង** នោះបានប្រាប់បងថ្លៃខ្លួនថា នឹងឲ្យលុយខ្លួន ៥០.០០០ បាទ តែខ្លួនមិនទាន់បានទទួលលុយនោះទេ។ ថ្នាំនោះដាក់នៅក្នុងហោប៉ៅបិទជិត ខ្លួនព្យាយាមបើកមើលដែរ តែមិនអាចបើកមើលបាន។ សំណូមពរឲ្យតុលាការលើកលែងទោសប្រកាន់លើរូបខ្លួនផង។

**-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖** ក្រោយពីបានពិនិត្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីរ ឃើញថា បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ អាចទទួលជំនុំជម្រះបាន។ ឆ្លងតាមការពិភាក្សាដេញដោលឃើញថា ជនជាប់ចោទទាំងពីរ បានរៀបរាប់ពីដំណើរការនៃការព្រមព្រៀងដឹកជញ្ជូនថ្នាំទៅប្រទេសជប៉ុន ដែលទទួលបានកម្រៃដែលជនជាប់ចោទឆ្លើយទៅចំពោះមុខសមត្ថកិច្ច គឺម្នាក់ៗទទួលបាន ៣.០០០ ដុល្លារអាមេរិក ដើម្បីយកថ្នាំនោះទៅប្រទេសជប៉ុន រហូតឈានដល់ការណាត់ជួបគ្នា ដើម្បីទទួលទំនិញយកទៅប្រទេសជប៉ុន។ ថ្វីដ្បិតតែជនជាប់ចោទបានឆ្លើយថា គាត់មិនបានដឹងថា ថ្នាំនោះ ជាថ្នាំញៀន ប៉ុន្តែផ្អែកតាមរបាការណ៍ ក៏ដូចជាចម្លើយដែលបានឆ្លើយទៅចំពោះមុខសមត្ថកិច្ច អាចសន្និដ្ឋានបានថា គាត់អាចដឹងមុនថា ថ្នាំនោះជាថ្នាំញៀន។ ផ្អែកតាមកំណត់ហេតុត្រួតពិនិត្យអ្នកដំណើររបស់មន្ត្រីគយ និងរដ្ឋាករ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺពិតជាបានឃើញថ្នាំញៀនលាក់ទុកក្នុងអាវរងារបស់ជនជាប់ចោទទាំងពីរពិតប្រាកដមែន។ ផ្អែកតាមវត្ថុតាងថ្នាំញៀនដែលសមត្ថកិច្ចបានដកហូត ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងផ្អែកតាមភស្តុតាងនានាក្នុងសំណុំរឿង តំណាងមហាអយ្យការយល់ឃើញថា ពិតជាមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទដូចតំណាងអយ្យការធ្វើការចោទប្រកាន់មែន។ ដូច្នេះ ស្នើសុំឲ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសតាមច្បាប់។

**-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា៖** ឆ្លងតាមការពិភាក្សាដេញដោលនាពេលសវនការ និងឯកសារនានាក្នុងសំណុំរឿង កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការបោកបញ្ឆោតពីឈ្មោះ **ភ្វាង** ធ្វើឲ្យកូនក្តីខ្លួនធ្វើដំណើរមកប្រទេសកម្ពុជា ដោយស្នាក់នៅខេត្តសៀមរាប។ ឈ្មោះ **ភ្វាង** បានរៀបចំថ្នាំញៀន តែមិនបានប្រាប់កូនក្តីខ្លួនថាជាថ្នាំញៀនទេ ដោយប្រាប់ថា ជាថ្នាំជំនួយផ្លូវភេទបុរស។ ដូច្នេះ កូនក្តីខ្លួនក៏មិនបានឆែកមើលក្នុងអាវរងាដែរ ហើយក៏មើលមិនឃើញពីខាងក្រៅថាជាថ្នាំញៀននោះដែរ។ ដោយសារការជឿទុកចិត្តលើ



Scanned with CamScanner

ឈ្មោះ ក្វាង ថាមិនបោកប្រាស់ខ្លួន ហើយឈ្មោះ [redacted] RUTHAIRAT [redacted] រ៉ូថៃរ៉ាត់) ដោយសារជឿទុកចិត្ត បងថ្លៃ ក៏មិនបានបើកមើលដែរ។ នៅពេលដែលសមត្ថកិច្ចឆែកឆេរឃើញថ្នាំញៀននោះ ទើបកូនក្តីខ្លួនដឹងថា ជាថ្នាំញៀន។ ផ្អែកតាមអង្គច្បាប់ កូនក្តីខ្លួនមិនបានដឹងថា ក្នុងអាវរងានោះ ជាថ្នាំញៀនទេ ដូច្នេះផ្អែកតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា គ្មានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ សំណូមពរក្រុមប្រឹក្សាលើកលែងការចោទប្រកាន់ទាំងពីរនាក់ផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទទាំងពីរ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍ភ្នំពេញ

## យល់ឃើញថា

១-សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: **១៧៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩** របស់លោក **ឈាវ ហ្វូឡាយ** មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] **វ៉ូរ៉ាផា**) និងឈ្មោះ [redacted] RUTHAIRAT ([redacted] **រ៉ូថៃរ៉ាត់**) សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ គ្រង់ចំណុច **នៃសេចក្តីសម្រេចទាំងមូល** នៃសេចក្តីសម្រេច បានធ្វើឡើងត្រឹមត្រូវក្នុងកំណត់ច្បាប់ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញទទួលសំណុំរឿងនេះជំនុំជម្រះបាន យោងតាមមាត្រា **៤៣** នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា **៣៨២ថ្មី** នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] WORAPHA (**ទុងកន វ៉ូរ៉ាផា**) បានឆ្លើយនាពេលសវនាការថា៖ ខ្លួនប្តឹងឧទ្ធរណ៍នេះ ព្រោះនៅខាងប្រទេសថៃបានចាប់បានឈ្មោះ **ក្វាង** ហើយ ហើយខ្លួនចង់ទៅប្រទេសថៃវិញ។ ខ្លួនមិនបានដឹងថាអាវរងារនោះមានលាក់បង្កប់ថ្នាំញៀននោះទេ ពីព្រោះឈ្មោះ **ក្វាង** បានប្រាប់ថា ក្នុងអាវរងារនោះមានលាក់បង្កប់ថ្នាំកម្លាំង គឺសម្រាប់ជំនួយផ្លូវភេទ។ ខ្លួនបានទៅជួបឈ្មោះ **ក្វាង** និងបុរសម្នាក់ទៀត ជាជនបរទេស នៅខេត្តសៀមរាប។ ពេលនោះឈ្មោះ **ក្វាង** បានយកអាវរងារចំនួន០៣ ដែលមានពណ៌ខ្មៅចំនួន០២ និងពណ៌ប្រផេះចំនួន០១ ហើយមានថ្នាំសម្រើប ដែលលាក់ទុកបង្កប់នៅខាងក្នុង។ ក្រោយមក ខ្លួនក៏បានយកអាវទាំងបីខាងលើមកសណ្ឋាគារដើម្បីរៀបចំដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ខ្លួនចំនួន០១ និងបានដាក់ចូលទៅក្នុងកាបូបយួរដៃរបស់ប្អូនថ្លៃខ្លួនចំនួន០២។ លុះដល់វេលាម៉ោងដប់បួន ពួកខ្លួនក៏បានចាកចេញពីសណ្ឋាគារ ឡើងជិះរថយន្តតាក់ស៊ីដែលឈ្មោះ **ក្វាង** ជាអ្នករៀបចំ ធ្វើដំណើរឆ្ពោះទៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ ហើយបានមកដល់ព្រលានយន្តហោះ នៅវេលាម៉ោងដប់ប្រាំបួន រួចក៏បានត្រួតពិនិត្យចូល (CHECK IN) ហើយក៏បន្តទៅត្រួតពិនិត្យវ៉ាលីនិងកាបូបយួរដៃខាងលើបន្ថែមទៀត។ ដោយសមត្ថកិច្ចមានការសង្ស័យទៅលើកាបូបយួរដៃរបស់ខ្លួន និងប្អូនស្រីថានៅក្នុងអាវរងារ ក៏បានធ្វើការហែកត្រួតពិនិត្យបានរកឃើញ ក្រាមពណ៌ស ជាច្រើនថង់លាក់បង្កប់ក្នុងអាវទាំងបី



Scanned with CamScanner

បន្ទាប់មកសមត្ថកិច្ចក៏បានយកក្រោមនោះមកធ្វើតេស្តនៅចំពោះមុខខ្លួន បង្ហាញថាវាជាគ្រឿងញៀន ប្រភេទមេតំហ្វេតាមីន (ICE) រួចក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។ ខ្លួនស្គាល់ឈ្មោះ **ភ្វាង** ប្រហែលជា ១០ ជាងហើយ។ ឈ្មោះ **ភ្វាង** បានរៀបចំឱ្យខ្លួនទៅប្រទេសជប៉ុនបានម្តង ដោយឈ្មោះ **ភ្វាង** ជាអ្នកចំណាយទាំងអស់។ ក្នុងការយកថ្នាំសម្រើបនេះទៅប្រទេសជប៉ុនឈ្មោះ **ភ្វាង** សន្យាថាឱ្យលុយពួកខ្លួនម្នាក់ៗ ៥០.០០០បាត នៅពេលដែលត្រឡប់មកពីប្រទេសជប៉ុនវិញ។ ខ្លួនមិនទាន់ទទួលបានលុយនោះទេ។ អាវរងានោះ ក្រាស់ ខ្លួនមិនអាចមើលឃើញថ្នាំញៀននៅក្នុងអាវទេ តែខ្លួនដឹងថាវាជាថ្នាំសម្រើប។ ខ្លួនទទួលស្គាល់ថា ថ្នាំនោះខ្លួនជាអ្នកយកទៅ តែខ្លួនមិនបានដឹងថា ជាថ្នាំញៀននោះទេ។ ខ្លួនគឺកសិករ ដែលមានចំណូលក្នុងមួយឆ្នាំ ប្រហែល ១០០.០០០ បាត។ ខ្លួនទទួលស្គាល់ចម្លើយ ដែលបានឆ្លើយនៅសាលាដំបូង។ សំណូមពរឱ្យតុលាការលើកលែងចោទប្រកាន់លើរូបខ្លួនផង។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា និងសម្រេចតាមច្បាប់។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] RUTHAIRAT ([redacted] **រ៉ូថៃរ៉ាត់**) បានឆ្លើយនាពេលសវនាការថា៖ ខ្លួនត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] WORAPHA ([redacted] **វ៉ូរ៉ាផា**)។ ខ្លួនបានទៅប្រទេសជប៉ុនបាន ១ដង ហើយលើកនេះ ជាលើកទី២។ ខ្លួនទទួលស្គាល់អង្គហេតុដែលបងថ្លៃខ្លួនបាននិយាយ។ ខ្លួនមានអាវរងានោះ ២ ព្រោះមួយទុកឱ្យកូនខ្លួនពាក់។ ឈ្មោះ **ភ្វាង** នោះបានប្រាប់បងថ្លៃខ្លួនថា នឹងឱ្យលុយខ្លួន ៥០.០០០ បាទ តែខ្លួនមិនទាន់បានទទួលលុយនោះទេ។ ថ្នាំនោះដាក់នៅក្នុងហោប៉ៅបិទជិត ខ្លួនព្យាយាមបើកមើលដែរ តែមិនអាចបើកមើលបាន។ សំណូមពរឱ្យតុលាការលើកលែងចោទប្រកាន់លើរូបខ្លួនផង។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា និងសម្រេចតាមច្បាប់។

**៤-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា:** ក្រោយពីបានពិនិត្យបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទទាំងពីរ ឃើញថា បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ អាចទទួលជំនុំជម្រះបាន។ ឆ្លងតាមការពិភាក្សាដេញដោលឃើញថា ជនជាប់ចោទទាំងពីរ បានរៀបរាប់ពីដំណើរការនៃការព្រមព្រៀងដឹកជញ្ជូនថ្នាំទៅប្រទេសជប៉ុន ដែលទទួលបានកម្រៃដែលជនជាប់ចោទឆ្លើយនៅចំពោះមុខសមត្ថកិច្ច គឺម្នាក់ៗទទួលបាន ៣.០០០ ដុល្លារអាមេរិក ដើម្បីយកថ្នាំនោះទៅប្រទេសជប៉ុន រហូតឈានដល់ការណាត់ជួបគ្នា ដើម្បីទទួលទំនិញយកទៅប្រទេសជប៉ុន។ ថ្វីត្បិតតែជនជាប់ចោទបានឆ្លើយថា គាត់មិនបានដឹងថា ថ្នាំនោះ ជាថ្នាំញៀន ប៉ុន្តែផ្អែកតាមរបាការណ៍ ក៏ដូចជាចម្លើយដែលបានឆ្លើយនៅចំពោះមុខសមត្ថកិច្ច អាចសន្និដ្ឋានបានថា គាត់អាចដឹងមុនថា ថ្នាំនោះជាថ្នាំញៀន។ ផ្អែកតាមកំណត់ហេតុត្រួតពិនិត្យអ្នកដំណើររបស់មន្ត្រីគយ និងរដ្ឋាករ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ គឺពិតជាបានឃើញថ្នាំញៀនលាក់ទុកក្នុងអាវរងារបស់ជនជាប់ចោទទាំងពីរពិតប្រាកដមែន។ ផ្អែកតាមវត្ថុតាងថ្នាំញៀនដែលសមត្ថកិច្ចបានដកហូត ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ និងផ្អែកតាមភស្តុតាងនានាក្នុងសំណុំរឿង តំណាងមហាអយ្យការយល់ឃើញថា ពិតជាមានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទដូចតំណាងអយ្យការធ្វើការចោទប្រកាន់មែន។ ដូច្នេះ ស្នើសុំឱ្យក្រុមប្រឹក្សាពិនិត្យ និងសម្រេចផ្តន្ទាទោសតាមច្បាប់។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា និងសម្រេចតាមច្បាប់។



Scanned with CamScanner

៥-មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថាៈ ឆ្លងតាមការពិភាក្សាដេញដោលនាពេលសវនការ និងឯកសារនានាក្នុងសំណុំរឿង កាលពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨ ដោយមានការបោកបញ្ឆោតពីឈ្មោះ ក្វាង ធ្វើឲ្យកូនក្ដីខ្លួនធ្វើដំណើរមកប្រទេសកម្ពុជា ដោយស្នាក់នៅខេត្តសៀមរាប។ ឈ្មោះ ក្វាង បានរៀបចំថ្នាំញៀន តែមិនបានប្រាប់កូនក្ដីខ្លួនថាជាថ្នាំញៀនទេ ដោយប្រាប់ថា ជាថ្នាំជំនួយផ្លូវភេទបុរស។ ដូច្នេះ កូនក្ដីខ្លួនក៏មិនបានឆែកមើលក្នុងអាវរងាដែរ ហើយក៏មើលមិនឃើញពីខាងក្រៅថាជាថ្នាំញៀននោះដែរ។ ដោយសារការជឿទុកចិត្តលើឈ្មោះ ក្វាង ថាមិនបោកប្រាស់ខ្លួន ហើយឈ្មោះ [redacted] RUTHAIRAT ([redacted] រ៉ូថៃរ៉ាត់) ដោយសារជឿទុកចិត្តបងថ្លៃ ក៏មិនបានបើកមើលដែរ។ នៅពេលដែលសមត្ថកិច្ចឆែកឆេរឃើញថ្នាំញៀននោះ ទើបកូនក្ដីខ្លួនដឹងថា ជាថ្នាំញៀន។ ផ្អែកតាមអង្គច្បាប់ កូនក្ដីខ្លួនមិនបានដឹងថា ក្នុងអាវរងានោះ ជាថ្នាំញៀនទេ ដូច្នេះផ្អែកតាមមាត្រា ៤ នៃក្រមព្រហ្មទណ្ឌ បានចែងថា គ្មានបទល្មើសទេ ប្រសិនបើគ្មានចេតនាប្រព្រឹត្ត។ សំណូមពរក្រុមប្រឹក្សាលើកលែងការចោទប្រកាន់ទាំងពីរនាក់ផង។ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញពិចារណា និងសម្រេចតាមច្បាប់។

៦-តាមលទ្ធផលនៃការពិភាក្សាដេញដោលខាងលើ សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញយល់ឃើញថាៈ តាមចម្លើយរបស់ជនជាប់ចោទ តាមកំណត់ហេតុត្រួតពិនិត្យអ្នកដំណើររបស់មន្ត្រីគយ និងរដ្ឋាករ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងតាមឯកសារជាភស្តុតាងនានាដែលមានក្នុងសំណុំរឿងឃើញថា ពិតជាមានពិរុទ្ធភាពដាក់បន្ទុកលើជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] វ៉ូរ៉ាផា) និងឈ្មោះ [redacted] RUTHAIRAT [redacted] រ៉ូថៃរ៉ាត់) ពីបទ **រក្សាទុក ដឹកជញ្ជូន និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** (ពីប្រទេសកម្ពុជាទៅកាន់ទីក្រុងតូក្យូប្រទេសជប៉ុន) ប្រព្រឹត្តនៅចំណុចស្ថានីយអ្នកដំណើរចេញនៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ កាលពីថ្ងៃ០៣ ខែមិថុនា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូចនេះសំអាងហេតុនៃសាលក្រមព្រហ្មទណ្ឌលេខៈ **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ បានបញ្ជាក់ស្រាប់ សាលាឧទ្ធរណ៍ភ្នំពេញឯកភាពតាមសំអាងហេតុខាងលើនេះ ដោយពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតឡើយ។

៧-សាលក្រមព្រហ្មទណ្ឌលេខៈ **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចសេចក្ដីមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីសភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ សម្រេចតម្កល់សាលក្រមខាងលើនេះ ទុកជាបានការដដែល ។

## **ហេតុដូច្នេះ**
## **វិនិច្ឆ័យសេចក្ដី**

**១.ទទួល** សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍លេខៈ **១៧៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩** របស់លោក [redacted] ហួឡាយ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] WORAPHA ([redacted] វ៉ូរ៉ាផា) និងឈ្មោះ [redacted] RUTHAIRAT ([redacted] រ៉ូថៃរ៉ាត់) ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះអង្គច្បាប់។

**២.តម្កល់** សាលក្រមព្រហ្មទណ្ឌលេខៈ **១១៣ ក១.ក្រ១១ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩** របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។



Scanned with CamScanner

៣.បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted]ORAPHA ([redacted] វ៉ូរ៉ាផា) និងឈ្មោះ [redacted] RUTHAIRAT [redacted] រូថៃរ៉ាត់) តាមនីតិវិធី។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ, ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងប្រកាសជាសាធារណៈ ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២១។

បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខ[redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

សាលាឧទ្ធរណ៍ភ្នំពេញ,ថ្ងៃទី២០ ខែតុលា ឆ្នាំ ២០២១

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]



Scanned with CamScanner